# ១៣

# ការបកស្រាយ ធម៌ព្រះពុទ្ធ  ខុសរបៀប ខុសពេលវេលា

*ត ទៅនេះជា យោបល់ផ្ទាល់របស់ខ្ញុំ បើលោកអ្នកមិនយល់ដូចខ្ញុំ សូមកុំទៅរករឿង គ្រូរបស់ខ្ញុំ ណាមួយលោកក៏ចាស់ទៀតផង។ ថ្វីបើព្រះអង្គគ្រូខ្ញុំ លោកជួយពិនិត្យក៏ ដោយ លោកពិនិត្យតែធម៌ព្រះពុទ្ធ ចំពោះការយល់របស់ខ្ញុំ គឺ ខ្ញុំជាអ្នកទទួលខុសត្រូវ ។*

**13-1** *ដោយមានពាក្យ* ***អនត្តា*** *ក្នុងធម៌ព្រះ ក៏បកស្រាយថា មិនមែនយើង មិនមែនខ្លួនយើង មិនមែនរបស់យើង*

*តាមខ្ញុំយល់ អនត្តា គឺចង់សំដៅថា អ្វីៗក្នុងលោកនេះសុទ្ធតែមិនទៀង ខ្លួនយើង ក៏មិនទៀង ខ្លួនកូនយើងក៏មិនទៀង ដូច្នេះ ដើម្បីកុំឲ្យកើតទុក្ខ នៅពេលណា ដែលរបស់នោះបាត់ទៅវិញ យើងកុំជាប់ជំពាក់នឹងរបស់ទាំងនោះ ។ ដូច្នេះ* **ធម៌ដែលប្រតិបត្តិ ចំពោះ អនត្តា គឺ មិនត្រូវមានចិត្តជាប់ជំពាក់**។ *មិនមែន គ្រាន់តែនិយាយ ថា ឥតមានខ្លួន ឥតមានយើង នោះក៏អស់ទុក្ខនោះទេ ។ ក្នុងការប្រាស្រ័យទាក់ទងគ្នា ត្រូវតែនិយាយ ថាខ្ញុំ ថាគេ ថាលោក ទើបស្របនឹង អ្វីៗដែលភ្នែកយើងឃើញ ។ យើងថា ឥតមានគេដូចម្ដេចកើត បើភ្នែកខ្ញុំមើលទៅឃើញរូបគេនៅនឹងមុខខ្ញុំ មានតែខ្វះភ្នែក ខ្ញុំចោល ។ បើធ្វើយ៉ាងនេះខុសពីច្បាប់ធម្មជាតិ ដែលមនុស្សតែងតែមានភ្នែក ។ ដោយ ធម៌ព្រះស្របតាមច្បាប់ធម្មជាតិ ការបកស្រាយណាមិនស្របនឹងច្បាប់ធម្មជាតិ ជាការ បកស្រាយធម៌ព្រះមិនត្រឹមត្រូវ ។ ត្រូវ ពន្យល់ថា យើងគ្រប់រូប ទាំងខ្ញុំ ទាំងលោកអ្នក បើមិនចង់មានទុក្ខ ត្រូវអប់រំចិត្ត* ***កុំឲ្យជាប់ជំពាក់នឹង ខ្លួនយើង នឹងកូនប្រពន្ធយើង*** *នឹង អ្វីៗទាំងអស់ក្នុងលោកនេះ ពីព្រោះទាំងយើង ទាំងគេ សុទ្ធតែមិនទៀង ។*

ក្នុងការប្រាស្រ័យទាក់ទង ត្រូវតែប្រើពាក្យសន្មត ពីព្រោះថាទុកជាយើងជុំនួស ពាក្យ « យើង ខ្ញុំ គេ ឯង » ដោយពាក្យបរមត្ថ « ខន្ធ៥ » ក៏ដោយ ក៏នៅសល់ពាក្យសន្មតដូចជា « ឡាន ឬ រថយន្ត » តើយើងរកពាក្យបរមត្ថ មកជុំនួសបានទេ ? ពីព្រោះពាក្យថា « ឡាន » ក៏ជាពាក្យសន្មតដែរ ដោយយើងពុំអាចចង្អុលប្រាប់គេបានថា **តើកន្លែងណាទៅដែលហៅថាឡាននោះ ?** បើយើងមើលទៅឃើញតែ កង់ ដែចង្កូត ឬ ទ្វារឡាន ជាដើម តែប៉ុណ្ណោះ។

ពាក្យថាឡាននេះ ជាពាក្យអរូបី សំដៅ **សំនុំ** មួយដែលនៅក្នុងនោះមានធាតុ ជាច្រើន ដូចជា កង់ ដែចង្កូត ទ្វារ ចង្កៀង ជាដើម ។ ដូច្នេះពាក្យថា **ឡាន** នេះ គឺទទេស្អាត ដូចជាពាក្យថា **ខ្ញុំ** ឬ **គេ ឯង** ជាដើមដែរ ។

<u>ដោយធម៌ អនត្តា ដដែលនេះ ក៏បកស្រាយថាអត់មាន អ្នកគិតទេ មានតែគំនិត ក៏ដូចអត់មានអ្នកធ្វើទេ មានតែអំពើ អត់មានអ្នកទទួលផលនៃអំពើទេ មានតែ អំពើ និង ផលនៃអំពើ ដែលកើតតៗគ្នា ទៅតាមច្បាប់ « **ហេតុ-ផល**» ក៏ដូច គ្រាប់ពូជ និង ដើមឈើ ដែលផ្លាស់ប្តូរគ្នាម្តងម្នាក់</u> ។

ទាំងនេះជាពាក្យដែល លោកគ្រូជំនាន់ដើម បានបកស្រាយរហូតមកដល់ពេលនេះ។ ខ្ញុំសូមយកតែឃ្លាចុងក្រោយមកអធិប្បាយ គឺឃ្លា <u>គ្រាប់ពូជ និង ដើមឈើ ដែលផ្លាស់ប្តូរគ្នាម្តងម្នាក់</u> បានន័យថា៖

គ្រាប់ពូជ ជាហេតុឲ្យដុះ ដើមឈើ យើងសរសេរ ៖ គ្រាប់ពូជ => ដើមឈើ ។ ហើយដោយប្តូរគ្នាម្តងម្នាក់គឺ ដើមឈើ ឲ្យគ្រាប់បានជា ពូជ យើងសរសេរ ៖ ដើមឈើ => គ្រាប់ពូជ ។ ដូច្នេះ ៖ គ្រាប់ពូជ => ដើមឈើ => គ្រាប់ពូជ => …… ។ សំណួររបស់ខ្ញុំគឺ បើមនុស្ស មិនយកគ្រាប់ទៅបណ្តុះ តើដើមឈើដុះឬទេ ?ដូចជា ពូជស្រូវ បើនៅតែក្នុងជង្រុក តើចេញជាសំណាប បានជាដើមស្រូវទេ ? នេះសរឲ្យ

ឃើញថា គ្រាប់ពូជ គ្រាន់តែជាហេតុមួយ ក្នុងចំណោមហេតុដទៃ ដែលនាំឲ្យមាន ដើមស្រូវ ហើយហេតុដទៃនោះគឺ មនុស្សដែលយកពូជស្រូវទៅត្រាំទឹក ។

13-2 ដោយមានពាក្យ **លោភ** ក្នុងធម៌ព្រះ ក៏ពន្យល់ថា កុំឲ្យលោភលន់ ។

ដល់បកស្រាយឲ្យល្អិតពេកទៅ ក៏ដល់ថ្នាក់ថា ការធ្វើបុណ្យកុសលក៏ជាការលោភ លន់ដែរ ពីព្រោះមានចេតនាចង់បាននេះ ចង់បាននោះ ដូចជាចង់បាន ទៅកើតឯ ឋានសួគ៌ ឬ ក៏សម្រេចនិព្វានជាដើម ។ តាមធម្មតា (ធម្មជាតិ) មនុស្សតែងតែចង់បាន របស់ដែលពេញចិត្ត នឹងស្អប់របស់ដែលមិនពេញចិត្ត ។ ហើយមនុស្សមានកម្លាំងពុះពារ ឧបសគ្គគ្រប់បែបយ៉ាង កាលណាមានចិត្តចង់បាន ដូចជាចង់ជាប់សញ្ញាប័ត្រក៏ ខំរៀនទាំងយប់ទាំងថ្ងៃ ។ ប្រសិនបើជាគ្មានចេតនាចង់ទៅ កើតឋានសួគ៌ទេ មនុស្ស ធ្វើម្តេចនឹងចង់ធ្វើបុណ្យធ្វើកុសល ធ្វើចង្ហាន់យកទៅប្រគេនព្រះសង្ឃ។ គ្រោះថ្នាក់ នៃលោភ គឺ មកពី លោភ ជាហេតុនៃ ទុក្ខ ហើយ លោភ ជាហេតុឲ្យកើតតណ្ហា ហើយ តណ្ហា ជាហេតុឲ្យកើត **ការជាប់ជំពាក់ (ឧបាទាន)**។ ដូច្នេះ ធម៌ដែលត្រូវភ័យខ្លាច ជាងគេ គឺ **ឧបាទាន** ។ នៅក្នុងធម៌បដិច្ចសមុប្បាទ តែហួស ឧបាទានហើយនោះវើ ខ្លួនលែងរួចហើយ ពីព្រោះត្រូវតែ <u>កើតស្លាប់-ស្លាប់កើត</u> តទៅទៀត វិលដូចកង់រទេះ រកចប់មិនឃើញទេ។

ចំពោះលោកអ្នកដែលពុំទាន់ស្គាល់ធម៌បដិច្ចសមុប្បាទ ខ្ញុំសូមអធិប្បាយដោយត្រួសៗ ដូចតទៅនេះ ។ បដិច្ចសមុប្បាទ ជាធម៌ដែលព្រះសង្ឃសូត្រនៅពេលធ្វើបុណ្យម្តងៗ ជាធម៌បង្ហាញ នូវ ហេតុនិងផល ដែលមានជាបន្តៗគ្នា ដោយ [ហេតុ => ផល ] ហើយ ផលនោះក៏ទៅជាហេតុដែលឲ្យផលបន្តទៅទៀត ទាំងអស់មាន ១២ អង្គ ដែលឲ្យ [ហេតុ-ផល ]ៗ របៀបនេះ គឺ ថា ៖ (**តារាង-1**)

| |
|---|
| អវិជ្ជា (1) => សង្ខារ (2) => វិញ្ញាណ (3) => នាមរូប (4) => សឡាយតនៈ(5) => ផស្សៈ (6) => **វេទនា (7)** => តណ្ហា (8) => **ឧបាទាន (9)** => **ភព** (10) => ជាតិ (11) => ជរាមរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ (12) ។ |

ក្នុង តារាង-1 ខាងលើនេះ គប្បីមើលថា អវិជ្ជា ជាហេតុ[1] សង្ខារ ជាផល ។ បន្ទាប់មក សង្ខារ ជាហេតុ ហើយ វិញ្ញាណ ជាផល ។ បន្ទាប់មក វិញ្ញាណ ជាហេតុ ហើយ នាមរូប ជាផល ។ បេះតែ តៗគ្នា រហូតដល់ ជាតិ ជាហេតុ ហើយ ជរាមរណៈ សោកៈ …ជាផល ។ ក្នុង តារាង-1 នេះដដែល ទុក្ខ (12) ជាផលនៃ ជាតិ(11) គឺការកើត ។ បានន័យថា កាលណាមាន ការកើត មាន ទុក្ខហើយ ។ នេះតាមធម៌ បដិច្ចសមុប្បាទ។ ដូច្នេះដើម្បីកុំឲ្យមាន ទុក្ខ ទាល់តែ កុំមានកំណើត ។ បើនិយាយពី ច្បាប់ ហេតុផល គឺ ហេតុ ឲ្យ ផល ហើយ ដើម្បី ផលរលត់ (រលត់ទុក្ខ) ទាល់តែ ហេតុរលត់ (រលត់ការកើត) ។

| | |
|---|---|
| ហេតុ => ផល (1) | |
| ហេតុ រលត់ => ផល រលត់ (2) | |

(**តារាង-2**)

ដោយយើងរាល់រូប សុទ្ធតែមិនចង់ជួបទុក្ខ ដូច្នេះ ដើម្បីកុំឲ្យមានទុក្ខ យើងត្រូវរំលត់ហេតុរបស់វា ។ ហេតុ មានហេតុជិត និង ហេតុឆ្ងាយ ។ តាមធម្មតាហេតុជិត ស្រួលរកជាងហេតុឆ្ងាយ ពីព្រោះហេតុជិតយើងអាចមើលឃើញភ្លាមៗ តែហេតុឆ្ងាយដែលជាឫសគល់ នៃផលខាងចុងនោះ ពិបាកនឹងរកខ្លាំងណាស់ ។ តែចំពោះយើង ដោយសារធម៌បដិច្ចសមុប្បាទរបស់ព្រះពុទ្ធ នោះហេតុជិតនិងហេតុឆ្ងាយ យើងមានទាំងអស់។ ផលខាងចុងគឺ ជរាមរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ (12) ហើយ

---

[1] ខ្ញុំ ដាក់ថា ហេតុ នេះ ជាការបកស្រាយរបស់ខ្ញុំដើម្បី ស្រួលយល់ខ្លះៗនោះទេ តែមិនអស់សេចក្តី ដូចធម៌ព្រះពុទ្ធទេ ។ ព្រះពុទ្ធទ្រង់ថែងថា ៖ **អវិជ្ជា បច្ចយា សង្ខារា** បកមកជាខ្មែរថា « ព្រោះមានអវិជ្ជា ជាបច្ច័យ ទើបមាន សង្ខារ » ។ ហើយដល់ខ្ញុំបកស្រាយ ខ្ញុំជំនួសពាក្យ ជាបច្ច័យ ដោយពាក្យ **ហេតុ** ហើយពាក្យ ទើបមាន ដោយពាក្យ **ផល** ។ តែពាក្យ ហេតុ នេះគ្រាន់តែន័យមួយ នៅក្នុងពាក្យ បច្ច័យ ។ ពីព្រោះបច្ច័យទាំងអស់ មាន២៤ ហើយហេតុនៅក្នុងពួក២៤នោះ ។

ហេតុឆ្ងាយបំផុត គឺ អវិជ្ជា (1) (មើល (**តារាង-1**)) ។

ដោយ (**តារាង-2**) ដើម្បី (12)[2] រលត់ ត្រូវ (1)[3] រលត់ ។ ពីព្រោះថាបើ (1) រលត់ នោះ(2) ក៏រលត់ ហើយ (2)រលត់ (3)ក៏រលត់ ដូច្នេះ ចេះតែរលត់តៗគ្នា រហូតដល់លេខ 12 ។ តែដោយគោរពច្បាប់ធម្មជាតិ មានហេតុខ្លះយើងមិនអាចធ្វើឲ្យរលត់បានដោយស្របនិងច្បាប់ធម្មជាតិនោះទេ ។ ឧបមា ដូចវេទនា(7) ជាដើម ដែលកើតកាលណាភ្នែកឃើញរូប ឬ ត្រចៀកឮសំឡេង ដូច្នេះដើម្បីឲ្យវេទនារលត់ ទាល់តែភ្នែកកុំឃើញរូប ឬ ត្រចៀកកុំឮ ។ តែមនុស្សតែងតែមានភ្នែកសម្រាប់មើល មានត្រចៀកសម្រាប់ឮ ហេតុនេះ

<u>**តើត្រូវរករបៀបយ៉ាងណាដើម្បីរំលត់ វេទនានេះ ?**</u>

ចម្លើយគឺនៅក្នុងច្បាប់ ហេតុ-ផល ដដែល ។ ដើម្បីឲ្យ វេទនា រលត់ ទាល់តែហេតុដែលនាំឲ្យកើតវេទនា នោះរលត់ ឬមួយ ហេតុទាំងឡាយដែលកើតមុនហេតុនោះ រលត់ជាមុនសិន ។ តាមធម៌ បដិច្ចសមុប្បាទ ហេតុមុនគេគឺ អវិជ្ជា (ហេតុទី១) ហើយហេតុក្រោយគេមុនដល់វេទនា គឺ ផស្ស: (ហេតុទី៦) នេះតាម (**តារាង-1**) ។ តាមតារាងនេះដែរ បើមាន « នាមរូប » ត្រូវតែមាន «វេទនា » ។ តែដើម្បី កុំឲ្យមាន នាមរូប ត្រូវកុំកើត ហើយដើម្បី កុំកើត ទាល់តែសម្រេច ព្រះនិព្វាន ដោយ រំលត់ អវិជ្ជា ។ ដោយព្រះនិព្វាននៅឆ្ងាយណាស់មិនងាយនឹងទៅដល់ទេ ពីព្រោះត្រូវការកសាងរាប់សែនកប្ប ដូច្នេះត្រូវរកហេតុផ្សេងទៀត ដែលយើងអាចរំលត់បានដោយងាយជាង។ នៅក្នុង (**តារាង-1**) ដដែលនេះមានហេតុ តណ្ហា (8) និង ឧបាទាន (9) ដែលយើងអាចបន្ថយ កម្លាំងវា បណ្តើរៗ ចាប់ពីជាតិនេះទៅ រហូតដល់បានសម្រេចព្រះនិព្វាន ជាទីអវសាន ។

---

[2] (12) គឺ លេខរៀងទី 12 ក្នុងតារាង-1 គឺ ជំនួសពាក្យ ជរាមរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ

[3] (1) គឺ លេខរៀងទី 1 ក្នុងតារាង-1 គឺ ជំនួសពាក្យ អវិជ្ជា ។ តទៅនេះខ្ញុំអាចប្រើ លេខ ជំនួសពាក្យក៏មាន ប្រសិនបើជាមិននាំឲ្យមានការច្រឡំ ។

ខ្ញុំសូមជូនអត្ថន័យរបស់អង្គ តណ្ហា ឧបាទាន និង ភព[4] តាមគម្ពីរ ៖

<u>ម្នាល ភិក្ខុទាំងឡាយ ចុះតណ្ហា(8) តើដូចម្ដេច</u> ?

ម្នាលភិក្ខុទាំងឡាយ ពួកតណ្ហានេះមាន ៦ គឺ រូបតណ្ហា១ សទ្ទតណ្ហា១ (សំឡេង) គន្ធតណ្ហា១ (ក្លិន) រសតណ្ហា១ (រសជាតិ) ផោដ្ឋព្វតណ្ហា១ (ការប៉ះកាយទៅនឹង របស់ខាងក្រៅខ្លួន) ធម្មតណ្ហា១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា តណ្ហា ។

<u>ម្នាល ភិក្ខុទាំងឡាយ ចុះឧបាទាន (9) តើដូចម្ដេច</u> ?

ម្នាលភិក្ខុទាំងឡាយ ឧបាទាននេះ មាន ៤ គឺ កាមុបាទាន១ (ជាប់និងកាម) ទិដ្ឋុបាទាន១ (ប្រកាន់មាំការយល់ខុះ) សីលព្វតុបាទាន១ (ប្រកាន់មាំលើពិធី) អត្តវាទុបាទាន១ (ប្រកាន់ថាមានអត្តា) ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឧបាទាន ។

---

[4] ដើម្បី យល់ភព និងយល់ធម៌ បដិច្ចសមុប្បាទ ឲ្យបានជ្រៅបន្តិច ខ្ញុំសូមដកស្រង់ អត្ថបទខ្លះនៅក្នុងសៀវភៅបដិច្ចសមុប្បាទ ដោយ ភិក្ខុ ជិន គេន [សៀវភៅយោង លេខ 4 ] ដែលមានដូចតទៅនេះ ៖ « សភាវធម៌ ដែលជាហេតុជាផល អាស្រ័យគ្នាកើតឡើងដូចច្រវាក់ជាប់គ្នាជារង្វង់មូល វិលទៅក្នុងវដ្ដសង្សារមិនមានទីបំផុត ប្រព្រឹត្តទៅតាមហេតុបច្ច័យ ប្រាសចាកសត្វបុគ្គល (អនត្តា) ដោយមិនមាននរណាជាអ្នកសាង នេះហៅថា **បដិច្ចសមុប្បាទ** »។ ក្នុង ១២អង្គនោះ មានចែកជា ៤ ក្រុម ដូចតទៅ ៖

1- អតីតហេតុ : អវិជ្ជា សង្ខារ

2- បច្ចុប្បន្នផល : វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា

3- បច្ចុប្បន្នហេតុ : តណ្ហា ឧបាទាន ភព

4- អនាគតផល : ជាតិ ជរា មរណៈ (សោក ។ល។ ) ។

<u>សង្កេត</u> ដោយបដិច្ចសមុប្បាទ ជាធម៌វិលក្នុងវដ្ដសង្សារ នៃសត្វលោក ហេតុដែលនាំវិលនេះ មាន អតីតហេតុ (មាន២) និង បច្ចុប្បន្នហេតុ (មាន៣) ។ អតីតហេតុ និង បច្ចុប្បន្នហេតុ ឲ្យផលជា អនាគតផល ។ [ **អតីតហេតុ និង បច្ចុប្បន្នហេតុ** ] => [ **អនាគតផល** ]

ដូច្នេះត្រូវ តែហេតុណាមួយរលត់ ទើបផលរលត់ គឺ ទើបចេញពីវដ្ដសង្សារនេះរួច ។

ម្នាល ភិក្ខុទាំងឡាយ ចុះភព (10) តើដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ ភពនេះ មាន ៣ គឺ កាមភព១ (ភពមានកាម គឺ អបាយភូមិ៤ មនុស្សភូមិ១ និង ទេវភូមិ៦) រូបភព១ (ភូមិព្រហ្មមានរូប១៦) អរូបភព ១ (ភូមិព្រហ្មឥតមានរូប៤) ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភព ។

ខ្ញុំរំលឹកធម៌ បដិច្ចសមុប្បាទ តែប៉ុណ្ណេះ សូមអញ្ជើញមើលសៀវភៅ បន្ថែមទៀតចុះ ពីព្រោះធម៌ បដិច្ចសមុប្បាទនេះ ព្រះមានព្រះភាគ ទ្រង់មនសិការ (ពិចារណា) ជាអនុលោម (នាំឲ្យកើត) ជាបដិលោម (នាំឲ្យរលត់) មិនមែនតែអស់បឋមយាមនៃរាត្រីប៉ុណ្ណោះទេ អស់មជ្ឈិមយាមនៃរាត្រីផង អស់បច្ឆិមយាមនៃរាត្រីផង គឺ អស់រាត្រីទាំងមូលតែម្តង [5]។ ព្រោះអ្វី ? ព្រោះធម៌ដែលព្រះអង្គបានត្រាស់ដឹងហើយ ជាធម៌ជ្រាលជ្រៅ (គម្ភីរោ) ជាធម៌ឃើញដោយកម្រ (ទុទ្ទសោ) ជាធម៌ដឹងតាមបានដោយកម្រ (ទុរនុពោធោ) ជាធម៌ស្ងប់ (សន្តោ) ជាធម៌ប្រណីត (បណីតោ) ជាធម៌ល្អិត (និបុណោ) ជាធម៌ ជាវិស័យដែលបណ្ឌិតគប្បីដឹង (បណ្ឌិតវេទនិយោ)។

ដូច្នេះ ក្នុងការពន្យល់ **ធម៌លោក** កុំចាំបាច់ហាមថា កុំឲ្យមានលោក ពីព្រោះនាំឲ្យគេយល់ច្រឡំ គេទៅជាខ្ជិលស៊ីដេកៗ ឲ្យម៉ែឪចិញ្ចឹម ឆ្វើយដាក់ថាមកពីធម៌ព្រះពុទ្ធថាកុំលោភ ។ ត្រូវនិយាយថា ព្រះលោកឲ្យយើងខំធ្វើការងារដោយសម្មាអាជីវោ ដើម្បីមានទ្រព្យសម្បត្តិ ។ ត្រូវចេះសន្សំទ្រព្យទុកដាក់សម្រាប់ថ្ងៃមុខ ពីព្រោះអ្វីៗក្នុងលោកនេះសុទ្ធតែមិនទៀង ជីវិតក៏មិនទៀង ទ្រព្យសម្បត្តិក៏មិនទៀង ថ្ងៃនេះរកបាន ថ្ងៃស្អែកអាចរកមិនបាន យើងមានលុយកាក់ត្រូវចេះសន្សំទុកគ្រាន់ដោះទ័លពេលមានអាសន្ន ។ ម្យ៉ាងទៀតយើងកុំជាប់ជំពាក់នឹងទ្រព្យសម្បត្តិនេះពេក ដើម្បីកុំឲ្យយើង

---

[5] **បដិច្ចសមុប្បាទ និង ឥទប្បច្ចយតា** រៀបរៀងដោយ ភិក្ខុ ជិន គេន វត្តពោធិវង្ស ប្រទេសបារាំង។

*ខកចិត្ត កាលណាវារត់ចោលយើង មកពីធម៌មិនទៀងនេះ ។ ត្រូវរំលែកទ្រព្យខ្លះយកទៅធ្វើបុណ្យ ជួយអ្នកដទៃ  ដើម្បីសន្សំកុសលទៅជាតិមុខ ដូចជាធ្វើបុណ្យដាក់ទានជាដើម ។ ធ្វើយ៉ាងនេះអ្នកនឹងបានសេចក្ដីសុខក្នុងជាតិនេះផងនិងទៅជាតិខាងមុខផង។ ខ្ញុំយល់ថា  លោភ ឬ មិនលោភ នៅលើចិត្ត  យើងគប្បីអប់រំចិត្តកុំឲ្យជាប់ជំពាក់នឹង អ្វីៗទាំងអស់ សូម្បីតែឋានសួគ៌ ដែលអាចទៅកើតបានដោយ កុសល ក៏កុំជាប់ជំពាក់ដែរ  ពីព្រោះយើងអាចធ្លាក់ពីឋានទេវតា ទៅកើតអបាយភូមិក៏បានដែរ ។*

*ខ្ញុំ មិនខ្វាចនិយាយថា ខ្ញុំមាន  អត្តា ឬ មាន លោភ ទេ បើខ្ញុំស្គាល់  អត្តា  ឬ លោភច្បាស់ហើយ ដូចជាអ្នកដែលស្គាល់ ពស់ច្បាស់ហើយ  គេមិនខ្វាចកាន់ក្បាលពស់ទេ ។ ដូចអ្នកខ្លះ ខឹងនឹងរដ្ឋាភិបាល អនុញ្ញាតឲ្យបើកកន្លែងលេងល្បែង កាស៊ីណូ* (casino) *។ តាមខ្ញុំយល់ បើយើងមិនចូលចិត្ត កាស៊ីណូ  យើងកុំទៅជិតវាទៅ ។ កាស៊ីណូវាមានមកចាប់ដៃយើង ឬ បង្ខំយើងឲ្យចូលទៅរកវាឯណា ។  យើងទេដែលថា ស្អប់វា  តែទៅជាប់ជំពាក់ចិត្តនឹងវា  នេះដូចយើងស្រែកថា  « ខ្ញុំស្អប់ឯងណាស់ »  តែនៅតែទៅអោបរបស់ដែលស្អប់នោះ ឲ្យស្អិតមើលតែស្កុរតាំងម៉ែ[6]។  បើត្រឡប់មក* **អនត្តា** *វិញ  យើងមិនហ៊ាននិយាយថាមាន អត្តាទេ តែត្រូវនិយាយថាមានតែខន្ធ៥  ដើម្បីឲ្យត្រូវតាមធម៌ព្រះ ។ តែតាមការពិតទុកជាថា « មានតែខន្ធ៥ »  ក៏ដោយ បើចិត្តនៅតែជាប់ជំពាក់នឹងខន្ធ៥ អោបខន្ធ៥ ឲ្យស្អិត  មិនព្រមស្រាយចំណង ដែលយើងចងដោយខ្លួនឯងចេញនោះទេ ទុក្ខនៅតែមានតទៅទៀតដដែល ។  សំខាន់នៅលើយើង តើយើងចង់ស្រាយចំណង ដែលយើងចងជាប់នឹងខន្ធ៥ ឬ ចងជាប់នឹងលោភនោះទេ ?  ពីព្រោះសព្វថ្ងៃនេះយើងនៅស្រឡាញ់ ខន្ធ៥ ឬ  លោភនៅឡើយ ។* ***ស្រឡាញ់ដោយរបៀបណា ?***

---

[6] *ខ្ញុំនិយាយនេះ  មិនមែនខ្ញុំមានចិត្តលំអៀងទៅខាងរដ្ឋាភិបាលទេ  តែខ្ញុំចង់ឲ្យលោកអ្នកដែលប្រព្រឹត្តល្បែងស៊ីសងពិចារណាទៅលើរឿងនេះផង ដើម្បីសេចក្ដីសុខសប្បាយរួចចាកទុក្ខរបស់យើង ។*

ដូចជា ស្រឡាញ់ អំណាច បុណ្យសក្តិ ចង់ឲ្យគេសរសើរគោរពបូជា (ដូចស្តេចដំនាន់ដើម ហ៊ានធ្វើអ្វីឲ្យប្រសើរជាងព្រះចេស្តា អ្នកឯងនឹងត្រូវវិនាសមិនខាន) ចង់មានមាសពេជ្រមកពាក់បង្អួតគេ ឲ្យគេសរសើរ ។ល។ ចាស់ហើយ ចង់កែកុន មុខមាត់លាបសក់ ឲ្យគេឃើញថានៅក្មេង ។ រួមសេចក្តីទៅ ការអប់រំចិត្តសំខាន់ ជាងការប្រើពាក្យបរមត្ថ ឬ ពាក្យសន្មត ឬ ការយល់ដោយបញ្ញា។ តាមការពិសោធន៍របស់ខ្ញុំការអប់រំចិត្ត គឺការបដិបត្តិ[7] តាមពាក្យទូន្មានរបស់ព្រះពុទ្ធ។

13-3 ដោយមានពាក្យ ចិត្ត កើតខ្លួនវា រលត់ខ្លួនវា ដូច្នេះយើងមិនអាចធ្វើអ្វីវាកើតទេ ។

បើថាយើង មិនអាចធ្វើអ្វីវាកើតទេ នោះបានសេចក្តីថា យើងទុកឲ្យចិត្តវាក្រឡុកយើងគ្មានឈប់ឈរទៅហើយ ៖ បើចិត្តចង់ផឹកស្រា យើងក៏បណ្តោយឲ្យវាផឹក បើចិត្តចង់ចាប់រំលោបប្រពន្ធកូនគេ យើងក៏បណ្តោយឲ្យវាចាប់រំលោបប្រពន្ធកូនគេ ។ ហើយដល់ក្រុមនគរបាលមកចាប់ យើងឆ្លើយថា មិនមែនខ្ញុំទេដែលចាប់ប្រពន្ធកូនគេនោះគឺចិត្តទេតើ ។ នេះហើយការយល់ធម៌ ការបកស្រាយធម៌ខុសទំនង ។ តាមពិត ចិត្តអាចអប់រំបាន ដោយយកចិត្ត ទៅអប់រំចិត្ត។ ឧទាហរណ៍ មានគរគោក នៅក្នុងធម៌ព្រះពុទ្ធដូចជា យកចិត្តមេត្តា ទៅអប់រំចិត្តទោសៈចិត្តកំណាញ់ យកសតិទៅអប់រំចិត្តរាយមាយចិត្តមិនស្ងប់ ជាដើម ។ ឧទាហរណ៍មួយទៀត គឺ សត្វដំរី ដែលធ្លាប់តែមានចិត្តសាហាវ ហ្មដំរីចេះ អប់រំចិត្តវា ឲ្យស្លូតរហូតដល់ប្រើឲ្យទាញឈើហ៊ុបបាន ។

កស្តុតាងមួយទៀត ប្រសិនបើជាយើងមិនអាចអប់រំចិត្តបាន ម្តេចក៏ព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់ឲ្យដំបូន្មានដល់យើងគ្រប់រូបថា៖

---

[7] មានតែចំណេះដែលយើងប្រើទេ ដែលនៅជាប់នឹងខ្លួនយើង ដោយយើងចាំមិនភ្លេច។

១- កុំធ្វើ អំពើអាក្រក់ ២- ធ្វើ អំពើល្អ ៣- ធ្វើចិត្ត ឲ្យបរិសុទ្ធ ។

13-4 និយាយពីការដោះស្បែកជើង

ការដោះស្បែកជើងនេះ មាននៅក្នុងព្រះពុទ្ធសាសនា ក៏ដូចមាននៅក្នុងសាសនាដទៃដូចជា សាសនាអ៊ីស្លាមជាដើម គឺត្រូវដោះស្បែកជើងមុននឹងចូលក្នុងព្រះវិហារ។

ខ្ញុំលើកយកការដោះស្បែកជើងក្នុងវត្ត មកនិយាយពេលនេះ ដោយខ្ញុំមានយោបល់មិនស្របនៅកន្លែងខ្លះ នៅពេលខ្លះ ។ ដូចជា ព្រះសង្ឃនិមន្តបិណ្ឌបាត ដើរទទេ ហើយលុយទឹកទៀត ពេលភ្លៀងលិចក្រុងភ្នំពេញម្តងៗ ។

ខ្ញុំសួរថា តើមានប្រយោជន៍អ្វី ក្នុងការគោរពបដិបត្តិធម៌ព្រះ ដោយមិនឲ្យព្រះសង្ឃពាក់ស្បែកជើង ពេលនិមន្តបិណ្ឌបាត ? ពីព្រោះព្រះពុទ្ធមិនបានឲ្យយើងគោរពធម៌ព្រះអង្គរហូតដល់ធ្វើបាបខ្លួន ដូចជាដេកហាលថ្ងៃនោះឡើយ ។ ដូច្នេះ ខ្ញុំយល់ថា ការដែលព្រះសង្ឃមិនពាក់ស្បែកជើង នៅពេលនិមន្តបិណ្ឌបាត ជាពលិកម្ម អត់ប្រយោជន៍ ហើយថែមទាំងនាំឲ្យមានរបួស ដូចជាមុតបន្លា ឬ មុតអំបែងកែវ នៅពេលលុយទឹកភ្លៀង។ មុននឹងឡើងជណ្តើរចូល ក្នុងកុដិ ឬ ក្នុងព្រះវិហារ យើងត្រូវតែដោះស្បែកជើង ពីព្រោះជាកន្លែងស្អាត ។ តែបើកន្លែងមិនស្អាត ដូចជាពេលហែ កឋិនទាន នៅជុំវិញព្រះវិហារ មានប្អូនស្រីជីដូនមួយខ្ញុំម្នាក់ គេថាឲ្យខ្ញុំដោះស្បែកជើង ហើយចាំគេកាន់ស្បែកជើងឲ្យខ្ញុំ ។ ខ្ញុំឆ្លើយថា បើខ្ញុំដោះស្បែកជើង ដើរជើងទទេជាន់ដី នោះជើងខ្ញុំនឹងប្រឡាក់ដី ហើយដល់ខ្ញុំដើរចូលក្នុងព្រះវិហារ នោះធ្វើឲ្យប្រឡាក់កន្ទេលដែលគេអង្គុយ តើសមទេ ? ប្រសិនបើជាមានទឹកលាងជើង មានក្រដាស ឬក្រណាត់ជូតជើង មុននឹងចូលក្នុងព្រះវិហារនោះខ្ញុំមិនប្រកែកទេ ។ ហេតុនេះខ្ញុំសុំពាក់ស្បែកជើងសិន នៅពេលហែអង្គកឋិន ហើយខ្ញុំនឹងដោះស្បែកជើងមុនឡើងជណ្តើរចូលក្នុងព្រះវិហារ ។

*សង្កេត*

*ចំពោះចម្លើយនៃសំណួរថា «តើស្លាប់ហើយ កើតទៀត ឬ មិនកើតទៀត » គឺមាននៅក្នុងធម៌ បដិច្ចសមុប្បាទ នេះហើយ តាមព្រះពុទ្ធសាសនា។ សត្វទាំងឡាយឯណា គឺមនុស្ស ឬ ទេវតា ឬ ព្រហ្ម បើមុននឹងស្លាប់ ចិត្ត នៅមាន តណ្ហានៅឡើយ សត្វទាំងឡាយនោះត្រូវតែកើតម្តងទៀត ហើយបើចិត្តនៃសត្វទាំងឡាយនោះ អស់តណ្ហាហើយ សត្វទាំងឡាយនោះ ឈប់កើតទៀតហើយ ។ ពីព្រោះ តាមទំព័រ ៩១ (តារាង-1) ៖*

តណ្ហា (8) => ***ឧបាទាន* (9)** => *ភព* (10) => ជាតិ(11) ។

*ដូច្នេះ* តណ្ហា *រលត់* => ជាតិ *រលត់* ។